# រំលឹកមេរៀន

ចូរជ្រើសរើសចម្លើយត្រូវខុសក្នុងល្បះខាងក្រោម៖

ខុស ១.នៅពេលដែលយើង ក្អក់ ឬកណ្តាស់ គឺជាអំពើ ឆន្ទៈ ។

ខុស ២.សេចក្តីប្រាថ្នាចង់ជ្រើសរើសអាជីព ឬជំនាញណាមួយ ជាអំពើឆន្ទៈផង និង អឆន្ទៈផង។

ត្រូវ បំណង សំដៅទៅលើអ្វីមួយដែលមនុស្សតាំងចិត្តចង់បាន ឬមានគម្រោងចង់ធ្វើ។

ត្រូវ ៤.គោលដៅ ស្មាត គឺបានបង្ហាញពីភាពជាក់លាក់ហើយឈានដល់ភាពជោគជ័យបាន។

# តើកត្តាសំខាន់ៗអ្វីខ្លះដែលឈានទៅដល់ការកំណត់គោលដៅជីវិតបានត្រឹមត្រូវ?

**កត្តាសំខាន់ៗ**

- ការឈ្វេងយល់ពីចំណង់ចំណូលចិត្ត
- ការត្រឡប់មកស្វែងរកនិស្ស័យធម្មជាតិរបស់ខ្លួន
- ការរកឃើញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួនឯង
- ភាពច្បាស់លាស់និងភាពជាក់លាក់លើគោលដៅ

- តើរូបភាពនេះបង្ហាញពីអ្វី?







# មេរៀនប្រចាំថ្ងៃ

## មុខវិជ្ជា៖សីលធម៌ពលរដ្ឋវិជ្ជា

ថ្នាក់ទី១២

### ជំពូកទី១៖តម្លៃមនុស្ស

### មេរៀនទី៦៖តម្លៃ និងសីលវិជ្ជា

បង្រៀនដោយអ្នកគ្រូ ៖ ហុក ធីតា

មកពីវិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី

# វត្ថុបំណង

១.កំណត់បានពីនិយមន័យតម្លៃតាមទស្សនអ្នកប្រាជ្ញមួយចំនួន
២.ពន្យល់បានពីទ្រឹស្តីនៃតម្លៃ

# ពន្យល់ពាក្យ

-អត្តនោម័ត :ការយល់ឃើញដោយគំនិតបុគ្គលម្នាក់ៗ

-សត្យានុម័ត :សេចក្តីពិត ការពិតប្រាកដ ដំណើរទៀងត្រង់

- **ដូចម្តេចដែល ហៅថាតម្លៃ?**

**តម្លៃ ជាលក្ខណៈនៃអ្វីៗដែលគេចង់បាន ឬជ្រើសរើសយក។**

**តាមទស្សនលោក រូឃីច តម្លៃ ជាជំនឿស្ថិតស្ថេរមួយដែលជាវិធីដាក់លាក់នៃការប្រព្រឹត្តិដែលគួរចូលចិត្ត ជាលក្ខណៈបុគ្គល និងលក្ខណៈសង្គម ។ តម្លៃមានភាពស្ថិតស្ថេរដោយសារតម្លៃមានស្ថេរភាពគ្រប់គ្រាន់។**

**លោក តើរី តម្លៃជាទំនាក់ទំនងពិសេសរវាងផលប្រយោជន៍ណាមួយ ជាមួយគោលបំណង និងលក្ខណៈពិសេសរបស់វា។**



# តើមានទ្រឹស្តីអ្វីខ្លះដែលពន្យល់ពីតម្លៃ



# បំណកស្រាយ

-ទ្រឹស្តីអត្តនោម័ត : លោក ចច សាន់តាយ៉ាណា និង ដេវីត ផាយើ តម្លៃត្រូវបានបង្ហាញតាមរយៈមនោសញ្ចេតនា ឥរិយាបទ ឬ ជំនឿ ដែលមនុស្សជួបប្រទះ ឬ ឆ្លងកាត់។ តម្លៃ ជាការវិនិច្ឆ័យផ្ទាល់ខ្លួនទៅលើវត្ថុ ឬស្ថានភាពណាមួយ។ ពួកអត្តនោម័ត តម្លៃមិនដាក់លាក់ទេ តម្លៃអាចប្រែប្រួលទៅតាមបុគ្គល ឬ ក្រុម។ ឧទាហរណ៍៖ គំនូរអាក្រាតកាយ។

# បំណកស្រាយ

-ទ្រឹស្តីសត្យានុម័ត : **លោក ផ្លេតូ និងអារីស្តូថល** តម្លៃជាសម្បត្តិ ឬគុណភាពពិតរបស់វត្ថុរបស់វត្ថុវិស័យភាព (តម្លៃពិតស្ថិតនៅក្រៅពិភពរបស់យើង មិនចំណុះនឹងញាណរបស់មនុស្សទេ ឧ. វត្ថុមួយមានតម្លៃរបស់វា ទោះបីយើងមិនឱ្យតម្លៃវាក៏ដោយ)





# បំណកស្រាយ

-ទ្រឹស្តីទំនាក់ទំនងនិយម ៖ តម្លៃមិនមែនជាសម្បត្តិទាំងស្រុងរបស់អ្វីមួយ ឬជាអំពើណាមួយទេ ហើយវាក៏មិនមែនជាការបង្កើតទាំងស្រុងរបស់មនុស្សដែរ ។ ទ្រឹស្តីទំនាក់ទំនងអះអាងបន្ថែមទៀតថា អត្ថិភាពនៃតម្លៃ តម្រូវឲ្យមានកត្តាបី ៖

- ✓មនុស្សដែលត្រូវជ្រើសរើសយកអ្វីមួយ
- ✓អ្វីមួយ ដែលគេចូលចិត្ត ឬត្រូវការ
- ✓បរិបទ ឬកាលៈទេសៈដែលក្នុងនោះការវាយតម្លៃកើតមានឡើង។

# តើប្រភេទផ្សេងៗនៃតម្លៃមានអ្វីខ្លះ?

ប្រភេទផ្សេងៗនៃតម្លៃមាន ៖

-តម្លៃសម្ភារៈ ជាតម្លៃនៃអ្វីមួយដែលកើតមានឡើង ដោយសារតែទំនាក់ទំនង របស់វាជាមួយនឹងអ្វីៗផ្សេងទៀត។ វត្ថុមួយមានតម្លៃ ពីព្រោះវាមានតួនាទីដែលវាបំពេញធ្វើឱ្យសម្រេចគោលបំណងជាក់លាក់ណាមួយ។

-តម្លៃពីធម្មជាតិ ជាតម្លៃដែលជាប់ទាក់ទងនឹងគុណភាព ឬលក្ខណៈដែលវត្ថុមានស្រាប់ រួមមាន សោភ័ណភាព ពុទ្ធិ សច្ចភាព សុភមង្គល សេចក្តីរីករាយ មិត្តភាព សេចក្តីគោរព ស្នាដៃសិល្បៈជាដើម។

# បំណកស្រាយ

លោក បិក្ខ និងហូលមីស បានធ្វចំណាត់ថ្នាក់នៃតម្លៃរបស់មនុស្សមាន ៖

-តម្លៃជីវសាស្រ្ត : ម្ហូបអាហារ សុខភាព

-តម្លៃសេដ្ឋកិច្ច :ទ្រព្យសម្បត្តិ សម្ភារះ

-តម្លៃឥទ្ធិពល : ការពេញចិត្ត ការចូលចិត្ត

-តម្លៃសង្គម : អំណាច ឋានះ មិត្តភាព





# បំណកស្រាយ

-តម្លៃបញ្ញា : ការចង់ចេះចង់ដឹង

-តម្លៃសោភ័ណ្ឌ : ការតុបតែងលម្អ ភាពប៉ិនប្រសប់

-សីលតម្លៃ : កុសលភាព គុណធម៌ សីលធម៌

-តម្លៃសាសនា : ជំនឿ ការគោរពសាសនា

ការបន់ស្រន់។





# តើមានទ្រឹស្ដីអ្វីខ្លះដែលពន្យល់ពីតម្លៃ?



# ពង្រឹងពុទ្ធិ

ចូរជ្រើសរើសចម្លើយត្រូវខុសក្នុងល្បះខាងក្រោម៖

ខុស ១. តម្លៃមិនមែនជាសម្បត្តិទាំងស្រុងរបស់អ្វីមួយ ឬជាអំពើណាមួយទេ ទ្រឹស្ដី អត្តនោម័ត

ត្រូវ ២. តម្លៃមិនមែនជាសម្បត្តិទាំងស្រុងរបស់អ្វីមួយ ឬជាអំពើណាមួយទេ ហើយវាក៏មិនមែនជាការបង្កើតទាំងស្រុងរបស់មនុស្សដែរ ជាទ្រឹស្ដីទំនាក់ទំនងនិយម។

ត្រូវ ៣. តម្លៃជាសម្បត្តិ ឬគុណភាពពិតរបស់វត្ថុរបស់វត្ថុវិស័យភាព ជាទ្រឹស្ដីសត្យានុម័ត ។

ខុស ៤. តម្លៃដែលជាប់ទាក់ទងនឹងគុណភាព ឬលក្ខណៈដែលវត្ថុមានស្រាប់ រួមមាន សោភ័ណភាព ជាតម្លៃសម្ភារៈ។



សូមអរគុណ!




QUESTIONS?
COMMENTS?
CONCERNS?